អាជ្ញាធរមីន
C.M.A.A

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

# របាយការណ៍
# ស្តីពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
# នៅខែវិច្ឆិកា ឆ្នាំ២០២៥

## សារតារ

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា ដែលគាំទ្រថវិកា ព្រមទាំងបច្ចេកទេសពីអង្គការជនពិការអន្តរជាតិបែលហ្ស៊ិក និងអង្គការយូនីសេហ្វ។

នៅដំណាច់ឆ្នាំ២០០៩ CMVIS ត្រូវបានផ្ទេរប្រគល់ពីកាកបាទក្រហមកម្ពុជា មកស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ និងការចែកចាយទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) នៅក្នុងប្រទេសកម្ពុជា។

### ព័ត៌មានស្តីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (មីន និងស.ផ.ស.)

### ១-ជនរងគ្រោះពីខែមករា ឆ្នាំ១៩៧៩ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥

ចាប់ពីខែមករា ឆ្នាំ១៩៧៩ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៦៥ ១២៤នាក់ ដែលបានកត់ត្រាដោយការិយាល័យ CMVIS ក្នុងនោះរួមមាន៖

- ជនរងគ្រោះដោយសារមីន ៥១ ២២៤នាក់(៧៩%) និងស.ផ.ស. ១៣ ៩០០នាក់(២១%)
- ជនរងគ្រោះស្លាប់ ១៩ ៨៤៥នាក់(៣០%) របួស ៣៦ ១៧៩នាក់(៥៦%) និងពិការអវយវៈ ៩ ១០០នាក់(១៤%)
- ជនរងគ្រោះជាបុរស ៥២ ៧៣១នាក់(៨១%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦ ១២៩នាក់(៩%) ស្ត្រី ៤ ៨០១នាក់(៨%) ក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១ ៤០០នាក់(២%) និងជនរងគ្រោះមិនស្គាល់អត្តសញ្ញាណ ៦៣នាក់(0%)។

### ២- ឧប្បត្តិហេតុគ្រោះថ្នាក់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០២៥

ចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០២៥ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ២៨ករណី ដែលតួលេខនេះមានការថយចុះ ៣% ប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៤ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ ២៩ករណី។

ក្នុងចំណោមឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៨ករណីរួមមាន៖ ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ១៦ករណី និងឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. ១២ករណី។

### ៣- ជនរងគ្រោះពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០២៥

ចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០២៥ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៣៨នាក់។ តួលេខនេះបានថយចុះ ១៩% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៤ ដែលមានជនរងគ្រោះចំនួន ៤៧នាក់។

ក្នុងចំណោមជនរងគ្រោះចំនួន ៣៨នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ១៨នាក់ និងជនរងគ្រោះដោយសារស.ផ.ស. ២០នាក់
- ជនរងគ្រោះស្លាប់ ១១នាក់ របួស ២៣នាក់ និងពិការអវយវៈ ៤នាក់
- ជនរងគ្រោះជាបុរស ២៦នាក់ ជាស្ត្រី ៤នាក់ ជាក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦នាក់ និងជាក្មេងស្រីអាយុក្រោម១៨ឆ្នាំ ២នាក់។

## ៤- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងខែវិច្ឆិកា ឆ្នាំ២០២៥

នៅខែវិច្ឆិកា ឆ្នាំ២០២៥ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ២ករណី ដែលក្នុងនោះគ្រោះថ្នាក់ដោយសារមីន ១ករណីបានកើតឡើងនៅខេត្តបន្ទាយមានជ័យ និងគ្រោះថ្នាក់ដោយសារស.ផ.ស. ១ករណីនៅខេត្តត្បូងឃ្មុំ។ តួលេខនេះដូចគ្នានឹងខែវិច្ឆិកា ឆ្នាំ២០២៤។

## ៥- ជនរងគ្រោះក្នុងខែវិច្ឆិកា ឆ្នាំ២០២៥

នៅខែវិច្ឆិកា ឆ្នាំ២០២៥ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ២នាក់។ តួលេខនេះមានចំនួនដូចគ្នានឹងខែវិច្ឆិកា ឆ្នាំ២០២៤។

- ជនរងគ្រោះរបួស ១នាក់ ដោយសារស.ផ.ស. និងពិការអវយវៈ ១នាក់ ដោយសារមីន
- ជនរងគ្រោះ ១នាក់ជាស្ត្រី និងជាបុរស ១នាក់
- សកម្មភាពពេលគ្រោះថ្នាក់គឺៈ ការដុតភ្លើង និងការធ្វើដំណើរ។

## ៦- ផលប៉ះពាល់ពីតំបន់គ្រោះថ្នាក់ពីខែមករា ឆ្នាំ២០២៤ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥ (ជនរងគ្រោះ ៨៧នាក់)

- ខេត្តចំនួន ៥ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៧% នៃជនរងគ្រោះសរុប
- ស្រុកចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៦៦% នៃជនរងគ្រោះសរុប
- ឃុំចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥២% នៃជនរងគ្រោះសរុប។

*ព័ត៌មានលម្អិត សូមមើលទំព័រទី៧*

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

## ទីតាំងគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅខែវិច្ឆិកា ឆ្នាំ២០២៥
## ឧប្បត្តិហេតុគ្រោះថ្នាក់: ២ករណី ជនរងគ្រោះ: ២នាក់




Produced by CMVIS, Dec 2025

ព័ត៌មានលម្អិតទាក់ទងនឹងព័ត៌មានអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ សូមទំនាក់ទំនងមកការិយាល័យ CMVIS តាមរយៈអាស័យដ្ឋានអ៊ីម៉ែល: ketya@cmaa.gov.kh

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

# របាយការណ៍ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះពីខែមករា ឆ្នាំ២០២២ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥

| | ជនរងគ្រោះតាមខែ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ/ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| **2022** | **11** | **9** | **7** | **7** | **5** | **1** | **0** | **0** | **0** | **0** | **0** | **1** | **41** |
| *ការបូកបណ្ដាក់ ឆ្នាំ2022* | *11* | *20* | *27* | *34* | *39* | *40* | *40* | *40* | *40* | *40* | *40* | *41* | |
| **2023** | **3** | **5** | **4** | **0** | **7** | **2** | **2** | **3** | **1** | **2** | **1** | **2** | **32** |
| *ការបូកបណ្ដាក់ ឆ្នាំ2023* | 3 | 8 | 12 | 12 | 19 | 21 | 23 | 26 | 27 | 29 | 30 | 32 | |
| *ការប្រែប្រួលភាគរយ 2022 ធៀប 2023* | -73 | -60 | -56 | -65 | -51 | -48 | -43 | -35 | -33 | -28 | -25 | -22 | |
| **2024** | **3** | **3** | **5** | **12** | **7** | **5** | **2** | **1** | **1** | **6** | **2** | **2** | **49** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2023* | 0 | -2 | 1 | 12 | 0 | 3 | 0 | -2 | 0 | 4 | 1 | 0 | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2023* | 0 | -40 | 25 | 100 | 0 | 150 | 0 | -67 | 0 | 200 | 100 | 0 | |
| *ការបូកបណ្ដាក់ ឆ្នាំ2024* | ***3*** | ***6*** | ***11*** | ***23*** | ***30*** | ***35*** | ***37*** | ***38*** | ***39*** | ***45*** | ***47*** | ***49*** | |
| *ការប្រែប្រួលភាគរយ 2023 ធៀប 2024* | 0 | -25 | -8 | 92 | 58 | 67 | 61 | 46 | 44 | 55 | 57 | 53 | |
| **2025** | **6** | **6** | **1** | **5** | **2** | **4** | **7** | **3** | **0** | **2** | **2** | | **38** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2024* | 3 | 3 | -4 | -7 | -5 | -1 | 5 | 2 | -1 | -4 | 0 | | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2024* | 100 | 100 | -80 | -58 | -71 | -20 | 250 | 200 | -100 | -67 | 0 | | |
| *ការបូកបណ្ដាក់ ឆ្នាំ2025* | ***6*** | 12 | ***13*** | ***18*** | ***20*** | ***24*** | ***31*** | ***34*** | ***34*** | ***36*** | ***38*** | | |
| *ការប្រែប្រួលភាគរយ 2024 ធៀប 2025* | 100 | 100 | 18 | -22 | -33 | -31 | -16 | -11 | -13 | -20 | -19 | | |

ចំណាំៈ តួលេខជនរងគ្រោះសម្រាប់ខែបន្តបន្ទាប់ទៀត នៃដំណើរការប្រមូលទិន្នន័យនឹងស្រាវជ្រាវឱ្យទាន់ពេលវេលា



ប្រព័ន្ធពត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

# ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ឆ្នាំ២០២៤ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥

## រាជធានីខេត្តត្រូវបានតម្រៀបតាមលំដាប់ចុះនៃផលបូកសរុបជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥

| | មករា24 | កុម្ភៈ24 | មីនា24 | មេសា24 | ឧសភា24 | មិថុនា24 | កក្កដា24 | សីហា24 | កញ្ញា24 | តុលា24 | វិច្ឆិកា24 | ធ្នូ24 | សរុប2024 | មករា25 | កុម្ភៈ25 | មីនា25 | មេសា25 | ឧសភា25 | មិថុនា25 | កក្កដា25 | សីហា25 | កញ្ញា25 | តុលា25 | វិច្ឆិកា25 | ធ្នូ25 | សរុប2025 | សរុប | ការបូកបណ្តាក់លើសរុប | ភាគរយនៃសរុប | ការបូកបណ្តាក់លើភាគរយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះខេត្ត | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | **2024-2025** | | | |
| បាត់ដំបង | 0 | 1 | 2 | 0 | 0 | 0 | 0 | 1 | 0 | 0 | 1 | 0 | **5** | 3 | 0 | 0 | 3 | 0 | 0 | 3 | 3 | 0 | 0 | 0 | 0 | **12** | **17** | 17 | 19.5 | 20 |
| ព្រះវិហារ | 0 | 0 | 0 | 0 | 2 | 2 | 0 | 0 | 0 | 0 | 0 | 0 | **4** | 0 | 0 | 1 | 0 | 0 | 1 | 4 | 0 | 0 | 2 | 0 | 0 | **8** | **12** | 29 | 13.8 | 33 |
| ឧត្តរមានជ័យ | 0 | 0 | 3 | 1 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | **5** | 2 | 0 | 0 | 1 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **4** | **9** | 38 | 10.3 | 44 |
| ពោធិ៍សាត់ | 3 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **4** | 0 | 1 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **2** | **6** | 44 | 6.9 | 51 |
| មណ្ឌលគិរី | 0 | 0 | 0 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **6** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **6** | 50 | 6.9 | 57 |
| បន្ទាយមានជ័យ | 0 | 2 | 0 | 0 | 1 | 1 | 0 | 0 | 1 | 0 | 0 | 0 | **5** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | **1** | **6** | 56 | 6.9 | 64 |
| កំពង់ធំ | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | **6** | 62 | 6.9 | 71 |
| កំពត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 6 | 0 | 0 | **6** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **6** | 68 | 6.9 | 78 |
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **4** | 72 | 4.6 | 83 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | **2** | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | **2** | **4** | 76 | 4.6 | 87 |
| កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | **2** | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **3** | 79 | 3.4 | 91 |
| ក្រចេះ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 1 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | **2** | 81 | 2.3 | 93 |
| សៀមរាប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | **2** | 83 | 2.3 | 95 |
| ប៉ៃលិន | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **1** | **2** | 85 | 2.3 | 98 |
| ព្រះសីហនុ | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 86 | 1.1 | 99 |
| ស្វាយរៀង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **1** | 87 | 1.1 | 100 |
| កំពង់ចាម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| កំពង់ស្ពឺ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| កណ្តាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| ព្រៃវែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| រតនគិរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| ស្ទឹងត្រែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| តាកែវ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| ភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 87 | 0 | 100 |
| សរុប | 3 | 3 | 5 | 12 | 7 | 5 | 2 | 1 | 1 | 6 | 2 | 2 | **49** | 6 | 6 | 1 | 5 | 2 | 4 | 7 | 3 | 0 | 2 | 2 | 0 | **38** | **87** | | | |

ក្រាហ្វិចជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមខេត្តនីមួយៗ នៅឆ្នាំ២០២៤-២០២៥



## ខេត្តចំនួន 5 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៤ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥

| លំដាប់ | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្រ្គាម | **ផលបូកសរុប អ្នករងគ្រោះ** | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|
| 1 | បាត់ដំបង | 8 | 9 | **17** | 17 |
| 2 | ព្រះវិហារ | 9 | 3 | **12** | 29 |
| 3 | ឧត្តរមានជ័យ | 9 | 0 | **9** | 38 |
| 4 | បន្ទាយមានជ័យ | 4 | 2 | **6** | 44 |
| 5 | ពោធិ៍សាត់ | 6 | 0 | **6** | 50 |

## ស្រុកចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៤ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥

| លំដាប់ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្រ្គាម | **ផលបូកសរុប អ្នករងគ្រោះ** | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|
| 1 | ជាំក្សាន្ត | ព្រះវិហារ | 9 | 3 | **12** | 12 |
| 2 | សំឡូត | បាត់ដំបង | 3 | 3 | **6** | 18 |
| 3 | ស្ទោង | កំពង់ធំ | 0 | 6 | **6** | 24 |
| 4 | បន្ទាយមាស | កំពត | 0 | 6 | **6** | 30 |
| 5 | វាលវែង | ពោធិ៍សាត់ | 6 | 0 | **6** | 36 |
| 6 | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 42 |
| 7 | បរិបូរណ៍ | កំពង់ឆ្នាំង | 0 | 4 | **4** | 46 |
| 8 | រតនៈមណ្ឌល | បាត់ដំបង | 3 | 1 | **4** | 50 |
| 9 | ត្រពាំងប្រាសាទ | ឧត្តរមានជ័យ | 4 | 0 | **4** | 54 |
| 10 | បាណន់ | បាត់ដំបង | 0 | 3 | **3** | 57 |

## ឃុំចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៤ ដល់ខែវិច្ឆិកា ឆ្នាំ២០២៥

| លំដាប់ | ឃុំ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្រ្គាម | **ផលបូកសរុប អ្នករងគ្រោះ** | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|---|
| 1 | ទូកមាសខាងលេច | បន្ទាយមាស | កំពត | 0 | 6 | **6** | 6 |
| 2 | មរកត | ជាំក្សាន្ត | ព្រះវិហារ | 5 | 1 | **6** | 12 |
| 3 | រមនា | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 18 |
| 4 | ថ្មដា | វាលវែង | ពោធិ៍សាត់ | 6 | 0 | **6** | 24 |
| 5 | ឆ្នុកទ្រូ | បរិបូរណ៍ | កំពង់ឆ្នាំង | 0 | 4 | **4** | 28 |
| 6 | ស្រអែម | ជាំក្សាន្ត | ព្រះវិហារ | 2 | 2 | **4** | 32 |
| 7 | រុងរឿង | ស្ទោង | កំពង់ធំ | 0 | 4 | **4** | 36 |
| 8 | អូរសំរិល | សំឡូត | បាត់ដំបង | 0 | 3 | **3** | 39 |
| 9 | អូរបីជាន់ | អូរជ្រៅ | បន្ទាយមានជ័យ | 3 | 0 | **3** | 42 |
| 10 | បាក់ខ្លង | មណ្ឌលសីម៉ា | កោះកុង | 1 | 2 | **3** | 45 |

# ការផ្ទុះបញ្ចាំងទូទៅលើជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អំឡុងពេល: មករា ឆ្នាំ២០២៤ - វិច្ឆិកា ឆ្នាំ២០២៥

ចំនួនសរុបនៃជនរងគ្រោះក្នុងអំឡុងពេលរាយការណ៍: ៨៧នាក់










## ការផ្ទុះបញ្ចាំងទូទៅលើករណីរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ












អំឡុងពេលៈ ខែមករា ឆ្នាំ២០២៤ - ខែវិច្ឆិកា ឆ្នាំ២០២៥

ចំនួនសរុបនៃជនរងគ្រោះ ក្នុងអំឡុងពេលរាយការណ៍ៈ ៨៧នាក់

## សកម្មភាពដែលបណ្តាលឱ្យគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ បែងចែកទៅតាមប្រភេទជនរងគ្រោះ




## សកម្មភាពរបស់ជនរងគ្រោះនៅពេលដែលគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### សកម្មភាពដែលបណ្តាលឱ្យផ្ទុះមីន




### សកម្មភាពដែលបណ្តាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម




## ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមលក្ខណៈភូមិសាស្ត្រដី

### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឱ្យផ្ទុះមីន




### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

